# កិច្ចព្រមព្រៀង

ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០២០ នៅក្រុមហ៊ុន **ដេស៊ីង ខេមបូ ខូអិលធីឌី** បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោក HAU RUIBIN ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារវត្ថុធាតុដើមដែលត្រូវផលិតត្រូវបានផ្អាកមិនអាចនាំចូលបាន និងផលិតផលដែលផលិតរួចហើយមិនអាចនាំចេញបាន ធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបានពេញលេញក្នុងរយៈ០២ខែ។

សមាសភាពចូលរួមៈ

1- ភាគីតំណាងរោងចក្រ

- លោក HAU RUIBIN តំណាងនាយករោងចក្រ
- លោក ផាន់ សុភ័ក្តិ ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោក ឡេង សំបូរ
- លោកស្រី ជូ សុខអៀង
- កញ្ញា មឿង បញ្ញា
- លោក អ៊ែល សុភាព
- លោកស្រី ពេជ្រ សុខខេង
- លោក ញ៉ែម ណាត
- លោកស្រី គង់ វីតា
- លោកស្រី ធួន សុខគា
- លោកស្រី ឃុត សុខឃាង

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោមៈ

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៨៨៦ នាក់ ក្នុងចំណោមកម្មករសរុបចំនួន ៨៨៦ នាក់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២០។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ជូន ៣០ដុល្លាអាមេរិក និងប្រាក់ឧបត្ថម្ភដែលរដ្ឋាភិបាលផ្តល់ជូន ៤០

ដុល្លា អាមេរិក ក្នុងមួយខែ ដោយយោងទៅតាមសេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារលេខៈ ០៤៥/ ២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

៣-ក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិក មួយខែម្តង ដូចខាងក្រោមៈ

ក-ប្រាក់ខែប្រចាំខែឧសភា បើកនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

ខ-ប្រាក់ខែប្រចាំខែមិថុនា បើកនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០

គ-ប្រាក់ខែប្រចាំខែកក្កដា បើកនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០

៤-ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង០៩:៥០នាទីនាថ្ងៃទី០៩ ខែឧសភាឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃសុក្រ ២ ខែពិសាខ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤

កំពង់ស្ពឺ,ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០

បានឃើញនឹងឯកភាព

តំណាងនាយកក្រុមហ៊ុន

DAESEUNG-CAMBO Co., Ltd

HAU RUIBIN

អ្នកកត់ត្រា

ផាន់ សុភ័ក្តិ

បានឃើញនឹងឯកភាព

តំណាងកម្មករ

ឡេង សំបូរ | ជូ សុខអៀង | មឿង បញ្ញា

អ៊ែល សុភាព | ពេជ្រ សុខខេង | ញ៉ែម ណាត

គង់ វីតា | ធួន សុខគា | ឃុត សុខឃាង